# សង្កាត់សាលារៀនអូកឡិនដ៍

## សេចក្តីជូនដំណឹងអំពីសវនាការសាធារណៈទាក់ទិនទៅនឹងសេចក្តីថ្លែងការណ៍ស្តីអំពីការមានគ្រប់គ្រាន់នៃសៀវភៅសិក្សា ឬសម្ភារៈបង្រៀនរបស់សង្កាត់សំរាប់ឆ្នាំសិក្សា 2008-2009

ជូនដល់ភាគីជាសមីទាំងអស់ សូមកត់សម្គាល់ថា នៅថ្ងៃទី 8 ខែតុលា 2008 សង្កាត់សាលារៀនអូកឡិនដ៍ នៅក្នុងកិច្ចប្រជុំធម្មតានៃអ្នកគ្រប់គ្រងថ្នាក់រដ្ឋ និង/ឬ គណៈនាយកនៃក្រសួងអប់រំ នឹងបើកសវនាការជាសាធារណៈមួយស្តីអំពីសេចក្តីថ្លែងការណ៍នៃការមានគ្រប់គ្រាន់នៃសៀវភៅសិក្សា ឬសម្ភារៈបង្រៀន សំរាប់ឆ្នាំសិក្សា 2008-2009 របស់ខ្លួនដែលត្រូវបានដាក់ស្នើសុំហើយនោះ។

សវនាការជាសាធារណៈនឹងត្រូវបានធ្វើនៅថ្ងៃទី 8 ខែតុលា 2008 នៅម៉ោង 6:00 ល្ងាច ឬក៏បើកក្នុងពេលឆាប់ៗបន្ទាប់ពីពេលហ្នឹងមកនៅក្នុងបន្ទប់នៃគណៈ ក្នុងអាគារ Paul Robeson, សង្កាត់សាលារៀនអូកឡិនដ៍, 1025 Second Avenue, Oakland, California 94606។ គោលបំណងនៃសវនាការនេះគឺសំរាប់ឲ្យគណៈគ្រប់គ្រងធ្វើការកំណត់ជាលាយលក្ខណ៍អក្សរថាតើកូនសិស្សម្នាក់ៗនៅក្នុងសាលារៀននិមួយៗក្នុងសង្កាត់នោះមានសៀវភៅសិក្សា ឬសម្ភារៈបង្រៀន (ឬទាំងពីរ) គ្រប់គ្រាន់ដែរឬយ៉ាងណា ស្របតាមស្តង់ដារមុខវិជ្ជាសិក្សា ដែលបានអនុម័តទៅតាមផ្នែកលេខ 60605 នៃក្រមអប់រំនៃមុខវិជ្ជានានាដូចតទៅនេះ ដែលស្របជាមួយមាតិការ និងស៊េរីនៃគម្រោងកម្មវិធីសិក្សាដែលគណៈគ្រប់គ្រងនៃក្រសួងអប់រំរបស់រដ្ឋបានអនុម័តយក :

គណិតសាស្ត្រ; វិទ្យាសាស្ត្រ; ប្រវត្តសាស្ត្រ-សង្គមវិទ្យា; និងភាសាសាស្ត្រអង់គ្លេសរួមមានសមាសភាគនៃកម្មវិធីអនុម័តលើការអភិវឌ្ឍភាសាអង់គ្លេស។

អ្នកគ្រប់គ្រងថ្នាក់រដ្ឋ និង/ឬ គណៈអប់រំ នៅក្នុងសវនាការ នឹងកំណត់ ជាលាយលក្ខណ៍ផងដែរថាតើកូនសិស្សម្នាក់ៗដែលចុះឈ្មោះរៀនភាសាបរទេស ឬថ្នាក់រៀនសុខភាពនោះ មានសៀវភៅសិក្សា ឬសម្ភារៈបង្រៀនគ្រប់គ្រាន់ដែរឬយ៉ាងណា ដែលស្របតាមមាតិការ និងស៊េរីនៃគម្រោងកម្មវិធីសិក្សាដែលគណៈគ្រប់គ្រងនៃក្រសួងអប់រំរបស់រដ្ឋបានអនុម័តយកមុខវិជ្ជាទាំងនោះ។ គណៈគ្រប់គ្រង នៅក្នុងសវនាការ នឹងកំណត់ជាលាយលក្ខណ៍ថែមទៀតលើការអាចរកបាននូវប្រដាប់ប្រដារពិសោធវិទ្យាសាស្ត្រ ដែលសមស្របសំរាប់ថ្នាក់រៀនពិសោធវិទ្យាសាស្ត្រ ដូចបានផ្តល់ឲ្យថ្នាក់ទី 9 ដល់ថ្នាក់ទី 12។

មាតាបិតា គ្រូបង្រៀន សមាជិកទាំងឡាយនៃសហគមន៍ដែលមានចំណាប់អារម្មណ៍លើកិច្ចការនានារបស់សង្កាត់ និងអ្នកដឹកនាំក្រុមចរចានោះ ត្រូវបានជំរុញឲ្យមកចូលរួមក្នុងសវនាការនេះ។

ផ្នែក 60119 នៃច្បាប់អប់រំកាលីហ្វូនញ៉ា តម្រូវអោយ គណៈគ្រប់គ្រង (ហៅកាត់ថា "គណៈ") នៃសង្កាត់សាលារៀនអូកឡិនដ៍ បើកសវនាការជាសាធារណៈប្រចាំឆ្នាំមួយ ដើម្បីកំណត់ពីការមានគ្រប់គ្រាន់នៃសៀវភៅសិក្សា ឬសម្ភារៈសំរាប់កិច្ចការបង្រៀន សំរាប់កូនសិស្សម្នាក់ៗក្នុងសាលារៀននិមួយៗ ដើម្បីអោយមានលក្ខខ័ណ្ឌគ្រប់គ្រាន់ក្នុងការទទួលថវិការសំរាប់គោលបំណងនានា ដូចបានរៀបរាប់ជូននៅខាងលើ ក្នុងវគ្គទីពីរនៃសេចក្តីជូនដំណឹងនេះ។ ការផ្តល់សៀវភៅសិក្សា សម្ភារៈបង្រៀន ឬប្រដាប់ប្រដារវិទ្យាសាស្ត្រ ដូចបានបញ្ជាក់ជូននៅក្នុងវគ្គទីបីនៃសេចក្តីជូនដំណឹងនេះ គឺពុំមែនជាល័ក្ខខ័ណ្ឌនៃការទទួលបាននូវថវិការ ដូចបានផ្តល់ឲ្យតាមរយៈកម្មវិធីផ្តល់សៀវភៅសិក្សា និងសម្ភារៈបង្រៀនសំរាប់កូនសិស្សទេ។

ការផ្តល់ទិន្នន័យថ្មីបំផុតអំពីរបាយការណ៍អំពីឋានៈនៃសម្ភារៈសិក្សាសំខាន់ៗ អំពីដំណោះស្រាយលើការកំណត់ដែលបានដាក់ស្នើសុំ និងអំពីអនុស្សរណៈរបស់គណៈសំរាប់ខែកញ្ញា 2008 មួយច្បាប់ គឺមានដាក់ជូនសំរាប់ពិនិត្យមើល មុនពេលបើក សវនាការជាសាធារណៈ តាមរយៈកំព្យូទ័រដែលមានដាក់ជូនអោយប្រើនៅក្នុង បន្ទប់ទទួលភ្ញៀវនៅជាន់ទីមួយ ហើយនិងនៅ ក្នុងការិយាល័យរបស់គណៈអប់រំ ក្នុងបន្ទប់លេខ 108 សង្កាត់សាលារៀនអូកឡិនដ៍, អាគារ Paul Robeson, 1025 2nd Avenue, Oakland, CA រវាងម៉ោង 9:00 ព្រឹកដល់ម៉ោង 4:00 រសៀល ពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ ហើយនិងនៅតាម បណ្តាញទូទាំងពិភពលោក : http://webportal.ousd.k12.ca.us/WebItem.aspx?WebItemID=23&TabID=32 មិនឲ្យហួសថ្ងៃទី 28 ខែកញ្ញា ឆ្នាំ 2008 នេះឡើយ។

s/Edgar Rakestraw, Jr.
លេខាធិការប្រចាំសង្កាត់
សង្កាត់សាលារៀនអូកឡិនដ៍

